**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៩៤០ ព.ណ.ភព..

ថ្ងៃសុក្រ ២កើត ខែជេស្ឋ ឆ្នាំម្សាញ់សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០២៥

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាធុរជន សហគ្រិន វិនិយោគិន និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន នឹងរៀបចំ **«ពិព័រណ៍ពាណិជ្ជកម្មទំនិញនាំចូលអន្តរជាតិចិន លើកទី៩- The 9th China International Import Expo ( CIIE )»** ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៥-១០ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន។

**«ពិព័រណ៍ពាណិជ្ជកម្មទំនិញនាំចូលអន្តរជាតិចិន»** គឺជាព្រឹត្តិការណ៍ពាណិជ្ជកម្មដ៏ធំមួយរបស់ប្រទេសចិន និងជាវេទិកាធុរកិច្ចដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ និងការទំនាក់ទំនងដៃគូពាណិជ្ជកម្មរវាងបណ្តាប្រទេសចូលរួមទាំងអស់ ជាមួយប្រទេសចិន។ ព្រឹត្តិការណ៍ពិព័រណ៍នេះក៏នឹងមានការរៀបចំសាងសង់ពន្លាជាតិ (Country Pavilion) របស់ប្រទេសចូលរួមនីមួយៗ ដែលក្នុងនោះ ក្រសួងពាណិជ្ជកម្មក៏នឹងបន្តរៀបចំសាងសង់ពន្លាជាតិកម្ពុជាផងដែរ។ បន្ថែមលើនេះ ពិព័រណ៍នេះ ក៏នឹងមានស្តង់ពិព័រណ៍ពាណិជ្ជកម្មដ៏សម្បូរបែប ដែលនឹងដាក់តាំងបង្ហាញផលិតផលរួមមាន៖ បរិក្ខារពេទ្យ ផលិតផលថែទាំសុខភាព រថយន្ត ឧបករណ៍បច្ចេកទេស ទំនិញប្រើប្រាស់ទូទៅ ផលិតផលកសិកម្ម ពាណិជ្ជកម្ម សេវាកម្ម និងផលិតផលនវានុវត្តន៍ជាដើម ព្រមទាំងមានរៀបចំវេទិកាពាណិជ្ជកម្មអមជាច្រើន។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួលព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមអញ្ជើញ លោក-លោកស្រី ដែលជាធុរជន សហគ្រិន វិនិយោគិន និងសាធារណជន ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមដាក់តាំងបង្ហាញផលិតផល/សេវាកម្ម ក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមទំនាក់ទំនងមកមន្ត្រីសម្របសម្រួលតាមរយៈទូរស័ព្ទលេខ +៨៥៥ ១៦ ៤១៦ ៨២៥ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦ ឬអ៊ីម៉ែល chao.katphuoy@moc.gov.kh ឬបំពេញបែបបទចូលរួមតាមរយៈ QR Code ខាងក្រោម៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ៖

https://go.gov.kh/moc/zo8v8l
GO.gov.KH

**KINGDOM OF CAMBODIA**

**Nation - Religion - King**

Ministry of Commerce

N° 0980 MOC. D/EA

Phnom Penh, 20 March 2026

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all businessmen, entrepreneurs, investors and the public that the Ministry of Commerce of the People's Republic of China is organizing **"The 9th China International Import Expo (CIIE)"**, to be held from 5-10 November 2026 in Shanghai, People's Republic of China.

**"The China International Import Expo (CIIE)"** is a major business event in China and an important business platform for international trade cooperation, investment and business partnership between all participating countries and China. The exposition will feature country pavilions, including the Cambodia Pavilion, which will once again be designed and constructed by the Ministry of Commerce. In addition, the event will contain a wide range of commercial booths showcasing medical equipment, healthcare products, automobiles, technical equipment, general consumer goods, agricultural products, trade in services and innovation products. A variety of business forums will also be held on the sidelines of the expo.

In this regard, the Ministry of Commerce, as a facilitator, would like to cordially invite all businessmen, entrepreneurs, investors and the public who are interested in participating and showcasing their products and services in the aforementioned exposition, please kindly contact the official in charge via:

Tel: +855 16 416 825

MOC Call Center: 1266

E-mail: chao.katphuoy@moc.gov.kh.

THANK YOU!

scan to register

GO.gov.kh

Ministry of Commerce, Lot 19-61, Russian Federation Blvd, Phum Teuk Thla,
Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

Phone/Facsimile: (855) 23 866 469